**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ: ៩៥៥ ស.ជ.ណ.ប.ស្ក

ថ្ងៃ ចន្ទ ៥ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសនិស្សិត មន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារ ជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងបរិស្ថានសម្រាប់ ឆ្នាំ២០១៩

ក្រសួងបរិស្ថាន មានកិត្តិយសសូមជូនដំណឹងដល់និស្សិត មន្ត្រីរាជការស៊ីវិលទាំងអស់ឱ្យបានជ្រាបថា ក្រសួបរិស្ថាន សម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើសនិស្សិត មន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងបរិស្ថាន សម្រាប់ឆ្នាំ២០១៩ ចំនួន ៤៧កន្លែង។

### ១. លក្ខខណ្ឌសម្រាប់ជ្រើសរើស

បេក្ខជនត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ១.១ ត្រូវមានសញ្ជាតិខ្មែរ
- ១.២ បេក្ខជនមានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុមិនឱ្យលើសពី ៣៥ឆ្នាំ (គិតត្រឹមថ្ងៃប្រឡង)
- ១.៣ បេក្ខជនមានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុមិនឱ្យលើសពី៤០ឆ្នាំ (គិតត្រឹមថ្ងៃប្រឡង)
- ១.៤ បេក្ខជនមានសញ្ញាបត្រថ្នាក់ បណ្ឌិត ឬសញ្ញាបត្រសមមូល និងមន្ត្រីរាជការស៊ីវិល ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- ១.៥ បេក្ខជនជាមន្ត្រីរាជការស៊ីវិល ត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើង និងមានលិខិតអនុញ្ញាតពីប្រធានក្រសួង ស្ថាប័ន។

### ២. អង្គភាពដែលត្រូវបម្រើការងារ

២.១. ទីស្តីការក្រសួង ក្របខណ្ឌប្រភេទ "ក" ចំនួន ២២ កន្លែង

| អង្គភាព | កន្លែង |
|---|---|
| ១. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | ០៣ |
| ២. អគ្គាធិការដ្ឋាន | ០២ |
| ៣. អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | ០៤ |
| ៤. អគ្គនាយកដ្ឋានគាំពារបរិស្ថាន | ០៤ |



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

| | |
|---|---|
| ៥. អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន | ០៣ |
| ៦. អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន | ០២ |
| ៧. អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | ០១ |
| ៨. នាយកដ្ឋានធនធានមនុស្ស | ០១ |
| ៩. នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ | ០១ |
| ១០. នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ០១ |

២.២. មន្ទីរបរិស្ថានរាជធានី-ខេត្ត ក្របខណ្ឌប្រភេទ"ក" ចំនួន ២៥ កន្លែង

| អង្គភាព | កន្លែង | អង្គភាព | កន្លែង |
|---|---|---|---|
| ១.រាជធានីភ្នំពេញ | ០១ | ១៤.ខេត្តកំពង់ចាម | ០១ |
| ២.ខេត្តកណ្តាល | ០១ | ១៥.ខេត្តត្បូងឃ្មុំ | ០១ |
| ៣.ខេត្តតាកែវ | ០១ | ១៦.ខេត្តក្រចេះ | ០១ |
| ៤.ខេត្តកំពត | ០១ | ១៧.ខេត្តរតនគិរី | ០១ |
| ៥.ខេត្តកែប | ០១ | ១៨.ខេត្តមណ្ឌលគិរី | ០១ |
| ៦.ខេត្តព្រះសីហនុ | ០១ | ១៩.ខេត្តស្ទឹងត្រែង | ០១ |
| ៧.ខេត្តកោះកុង | ០១ | ២០.ខេត្តព្រៃវែង | ០១ |
| ៨.ខេត្តបន្ទាយមានជ័យ | ០១ | ២១.ខេត្តស្វាយរៀង | ០១ |
| ៩.ខេត្តឧត្តរមានជ័យ | ០១ | ២២.ខេត្តកំពង់ឆ្នាំង | ០១ |
| ១០.ខេត្តប៉ៃលិន | ០១ | ២៣.ខេត្តពោធិ៍សាត់ | ០១ |
| ១១.ខេត្តព្រះវិហារ | ០១ | ២៤.ខេត្តបាត់ដំបង | ០១ |
| ១២.ខេត្តសៀមរាប | ០១ | ២៥.ខេត្តកំពង់ស្ពឺ | ០១ |
| ១៣.ខេត្តកំពង់ធំ | ០១ | | |

### ៣. វិញ្ញាសាប្រឡង

-វិញ្ញាសា ចំណេះដឹងទូទៅ (រយៈពេល ០២ម៉ោង)
-វិញ្ញាសា ជំនាញឯកទេសបរិស្ថាន (រយៈពេល ០២ម៉ោង)
-វិញ្ញាសា ភាសាអង់គ្លេស (រយៈពេល ០១ម៉ោង ៣០នាទី)

### ៤. កាលបរិច្ឆេទប្រឡង

-ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ចាប់ពីម៉ោង ៧:០០នាទីព្រឹក

### ៥. មណ្ឌលប្រឡង

-ទីស្តីការក្រសួងបរិស្ថាន (សាលប្រជុំ ម៉ុក ម៉ារ៉េត)

### ៦ .ការទទួលពាក្យ

ចាប់ផ្តើមទទួលពាក្យសុំសិទ្ធិប្រឡងចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រៀងរាល់ម៉ោងធ្វើការពេលព្រឹកចាប់ពីម៉ោង០៨:០០នាទីព្រឹក ដល់ម៉ោង១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:០០នាទី នៅនាយកដ្ឋានធនធានមនុស្សដែលមានទីតាំងស្ថិតនៅអគារមរកតេជោ ដីឡូ

លេខ៥០៣ ផ្លូវចាក់កៅស៊ូអមមាត់ទន្លេបាសាក់សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងនៅមន្ទីរបរិស្ថានរាជធានី ខេត្តចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩។

**បញ្ជាក់៖**
- បេក្ខជនដែលមានបំណងដាក់ពាក្យសុំប្រឡង សូមចូលទៅគេហទំព័រ www.moe.gov.kh ដើម្បីទាញយកពាក្យសុំសិទ្ធិប្រឡង។
- បេក្ខជនត្រូវមកដាក់ពាក្យសុំសិទ្ធិប្រឡងដោយខ្លួនឯងផ្ទាល់ និងបង់កម្រៃសុំសិទ្ធិប្រឡងចំនួន៤០,០០០រៀល (បួនម៉ឺនរៀល)ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ។

## ៧. បេក្ខជនត្រូវបំពេញសំណុំលិខិតក្នុងការដាក់ពាក្យប្រឡងរួមមាន៖

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. សេចក្តីចម្លងសញ្ញាបត្រដោយមានបញ្ជាក់ជាផ្លូវការ | ចំនួន ០១ច្បាប់ |
| ៣. ជីវប្រវត្តិសង្ខេបមានបិទរូបថត(៤ x ៦) | ចំនួន ០១ច្បាប់ |
| ៤. សលាកបត្រឯកត្តជន | ចំនួន ០១ច្បាប់ |
| ៥. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០១ច្បាប់ |
| ៦. សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ចំនួន ០១ច្បាប់ |
| ៧. លិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្ន(សេចក្តីចម្លងប័ណ្ណគ្រួសារ) | ចំនួន ០១ច្បាប់ |
| ៨. កិច្ចសន្យាបម្រើការងារក្រសួង | ចំនួន ០១ច្បាប់ |
| ៩. រូបថតថ្មី ៤ x ៦ ថតចំពីមុខ | ចំនួន០២សន្លឹក |
| ១០.លិខិតបញ្ជាក់កិរិយាមាយាទពី ឃុំ-សង្កាត់(ក្រោយប្រឡងជាប់) | ចំនួន ០១ច្បាប់ |
| ១១.លិខិតបញ្ជាក់សុខភាព និងកាយសម្បទា(ក្រោយប្រឡងជាប់) | ចំនួន ០១ច្បាប់ |

**សេចក្តីបញ្ជាក់៖**

- បេក្ខជន ជាជនពិការ និងស្ត្រី ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់អាទិភាព
- បេក្ខជន ត្រូវសរសេរបំពេញបែបបទសុំសិទ្ធិប្រឡងចុះហត្ថលេខា និងមកដាក់ពាក្យដោយខ្លួនឯងផ្ទាល់
- បេក្ខជន ត្រូវទៅធ្វើលិខិតបញ្ជាក់សុខភាពនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំពោះលិខិតថ្កោលទោស បេក្ខជនត្រូវប្រគល់ជូនក្រសួងក្រោយពីប្រឡងជាប់ជាស្ថាពរ។

## ៨. ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានលម្អិត សូមមកទាក់ទងនៅនាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថានរៀងរាល់ម៉ោងធ្វើការ ឬទំនាក់ទំនងតាមទូរស័ព្ទលេខ៖០១៧ ៧៨៨ ៤៧៧/ ០៨៩ ៩៦២ ៣១៣/០៦៩ ៣៤៤ ៤៧៩/០៩៨ ៥១៧ ៣៧៦។

អាស្រ័យហេតុនេះ សូមនិស្សិត មន្ត្រីរាជការស៊ីវិល និងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន សាលារាជធានី-ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួងបរិស្ថាន
- ឯកសារ កាលប្បវត្តិ